ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...០២...ស.រ.

## សារាចរ

## ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់

កន្លងមក ដីរដ្ឋ ទាំងដីសាធារណៈរបស់រដ្ឋ ទាំងដីឯកជនរបស់រដ្ឋ ភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីកំណត់ទីតាំង និងព្រំប្រទល់ច្បាស់លាស់ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅឡើយ ដែលធ្វើឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ប្រឈមនឹងការលំបាកក្នុងការគ្រប់គ្រង ដូចជាការទប់ស្កាត់ ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ជាដើម ។

ការចូលកាន់កាប់ដីតាមរូបភាពភោគៈ ត្រូវបានបញ្ចប់បន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមាន ក្នុងពេលដែលរដ្ឋមិនទាន់បានអនុវត្តទូលំទូលាយនៅឡើយនូវកម្មវិធីសម្បទានដីសង្គមកិច្ច សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដើម្បីដោះស្រាយសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋ ដែលចេះតែកើនឡើងជារៀងរាល់ថ្ងៃ ដោយសារកំណើនប្រជាជន ការវិសាលកងទ័ព ការបាត់បង់ដីដោយសារគ្រោះធម្មជាតិជាដើម ដែលជាហេតុនាំឱ្យមានការចូលកាន់កាប់ដីរដ្ឋ ដោយអនាធិបតេយ្យ ។ ទន្ទឹមនេះ ក៏មានជនឆ្លៀតឱកាស ពួកឈ្មួញដី និងអ្នកមានអំណាចមួយចំនួន បានចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់តាមរូបភាពផ្សេងៗ ។

ចំពោះមុខស្ថានការណ៍នេះ និងអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដែលទាក់ទងនឹងដីធ្លី ដូចជាច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ជលផល ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ និងព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងការគ្រប់គ្រងវបនីយជីវមណ្ឌលបឹងទន្លេសាប ជាដើម រាជរដ្ឋាភិបាលយល់ថា ដើម្បីដោះស្រាយបញ្ហាទន្ទ្រានកាន់កាប់ដីរបស់រដ្ឋដោយខុសច្បាប់កន្លងមក ពីសំណាក់បុគ្គលឯកជន ទន្ទឹមនឹងការអនុវត្តច្បាប់ ក៏ទាមទារនូវការពិនិត្យករណីរលោភជាក់ស្តែងនីមួយៗ និងដោះស្រាយដោយមានការអនុគ្រោះមួយចំនួន ពិសេសចំពោះគ្រួសារជនក្រីក្រ និងចំពោះដីធ្លីដែលបានធ្វើអាជីវកម្មពិតប្រាកដ ស្របតាមគោលនយោបាយដែលមានចែងក្នុងសារាចរនេះ ។ ដោយឡែក ចំពោះសម្បទានដីសេដ្ឋកិច្ច ករណីដែលសម្បទានិកមិនបានធ្វើការអភិវឌ្ឍតាមកិច្ចសន្យា ឬកាន់កាប់ដីសរុបលើសពីទំហំកំណត់នៃច្បាប់ភូមិបាល ការដកហូត ឬការកាត់បន្ថយ ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងក្នុងអនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច ។